ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖ ២៩៤/រប.សអលា
/២២

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបិទចរាចរណ៍ឆ្លងកាត់ខ្លោងទ្វារជ័យនៃអតីតរាជធានីអង្គរធំ និងស្ពានប្រាសាទតាកែវ ដើម្បីរៀបចំកម្មវិធី "ភូមិសង្ក្រាន្ត" នៃព្រឹត្តិការណ៍សៀមរាបសង្ក្រាន្ត ឆ្នាំ២០២២

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបថា ដើម្បីចូលរួមអបអរសាទរពិធីចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២២ ខាងមុខនេះ សហភាពសហព័ន្ធយុវជនកម្ពុជា នឹងរៀបចំកម្មវិធី "ភូមិសង្ក្រាន្ត" នៃព្រឹត្តិការណ៍សៀមរាបសង្ក្រាន្តឆ្នាំ២០២២ នៅបរិវេណប្រាសាទចៅសាយទេវតា និងប្រាសាទធម្មនន្ទ ចាប់ពីថ្ងៃទី១២ រហូតដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២២។ ក្នុងន័យដើម្បីឱ្យការរៀបចំកម្មវិធីខាងលើនេះ អាចប្រព្រឹត្តទៅដោយរលូន អាជ្ញាធរជាតិអប្សរា នឹងបិទការធ្វើចរាចរណ៍ឆ្លងកាត់ខ្លោងទ្វារជ័យនៃអតីតរាជធានីអង្គរធំ និងស្ពានប្រាសាទតាកែវ ដូចមានប្លង់ជូនភ្ជាប់មកជាមួយ **ចាប់ពីថ្ងៃទី១២ រហូតដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២២** ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃ ចន្ទ ១០កើត ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
សៀមរាប ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០២២
**អាជ្ញាធរជាតិអប្សរា**

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្គោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

# ផែនទីនៃដំណើរចរាចររបស់យានយន្ត ចេញ-ចូលទីតាំង
# កម្មវិធី «ភូមិសង្ក្រាន្ត» នៃព្រឹត្តិការណ៍សៀមរាបសង្ក្រាន្ត២០២២

